# ការប្តេជ្ញារបស់ អិលអូអិលស៊ី (ខេមបូឌា) លើសុវត្ថិភាព គុណភាព និងសេវាកម្មព័ត៌មាន

## សេចក្តីផ្តើម

អិលអូអិលស៊ី (ខេមបូឌា) ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេមួយក្នុងប្រទេសកម្ពុជា មានកិត្តិនាមក្នុងការផ្តល់ដំណោះស្រាយហិរញ្ញវត្ថុដែលឆ្លើយតបទៅនឹងតម្រូវការក្រុមគ្រួសារ សហគ្រិន និងអតិថិជនកម្ពុជា ដែលចង់ស្វែងរកឱកាសសេដ្ឋកិច្ចដើម្បីផ្លាស់ប្តូរគុណភាពជីវិត។ តាមរយៈការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ និងឆ្ពោះទៅរកគោលដៅចីរភាព អិលអូអិលស៊ី បានជំរុញការលូតលាស់ផ្នែកសេដ្ឋកិច្ច និងបង្កើតនូវលទ្ធផលវិជ្ជមានយូរអង្វែងនៅទូទាំងប្រទេសកម្ពុជា។

## សុវត្ថិភាពព័ត៌មាន

“អិលអូអិលស៊ី ប្តេជ្ញារក្សាសុវត្ថិភាពព័ត៌មាន និងការពារទ្រព្យសកម្មនៃព័ត៌មានវិទ្យារបស់ខ្លួនក្នុងពេលដែលអភិវឌ្ឍប្រព័ន្ធព័ត៌មានដែលប្រកបដោយប្រសិទ្ធភាព។ ការប្តេជ្ញារបស់យើងស្ថិតនៅក្នុងការអភិរក្សក្របខណ្ឌនៃសុវត្ថិភាពព័ត៌មានដ៏រឹងមាំ ដើម្បីធានាបាននូវការសម្ងាត់ ( Confidentiality ) ភាពគង់វង្ស ( Integrity ) និងភាពដែលអាចប្រើប្រាស់បាន ( Availability ) នៃទិន្នន័យនៅ អិលអូអិលស៊ី ។ លើសពីនេះ យើងនឹងប្រកាន់ខ្ជាប់នូវកាតព្វកិច្ចផ្លូវច្បាប់ បទប្បញ្ញត្តិ និងកិច្ចសន្យាដែលពាក់ព័ន្ធទាំងអស់។"

## គុណភាព

"ការប្តេជ្ញាចិត្តរបស់យើងគឺធ្វើឱ្យលើសពីការរំពឹងទុករបស់អតិថិជនដោយការផ្តល់ជូននូវសេវាកម្មព័ត៌មានវិទ្យាប្រកបដោយគុណភាពខ្ពស់ និងការបង្កើតកម្មវិធីដែលផ្តល់អាទិភាពដល់តម្រូវការរបស់ពួកគាត់ និងផ្តល់នូវគុណភាពល្អបំផុតដែលអាចធ្វើទៅបាន។"

## សេវាកម្ម

“យើងប្តេជ្ញាផ្តល់សេវាកម្មព័ត៌មានវិទ្យាដែលអាចទុកចិត្តបាន និងមានប្រសិទ្ធភាពស្របតាមតម្រូវការរបស់អតិថិជនយើង។ សេវាកម្មព័ត៌មានវិទ្យាទាំងអស់ត្រូវបានគ្រប់គ្រងដោយអនុលោមតាមនីតិវិធីផ្ទៃក្នុងដែលត្រូវបានណែនាំយ៉ាងច្បាស់ពីដំណើរការនៃសេវាកម្មទាំងនេះ និងធានាថាវាអាចដំណើរការបាន ២៤ម៉ោង សម្រាប់អតិថិជន។ យើងផ្តោតលើការរក្សានូវគុណភាព និងសុវត្ថិភាពនៃដំណើរការផ្តល់ជូនសេវាកម្មរបស់យើង។”

## ការប្តេជ្ញា

ដោយស្របតាមគោលនយោបាយរបស់ក្រុមហ៊ុន យើងបានពង្រឹងការប្តេជ្ញាចិត្តដោយសម្រេចបាននូវវិញ្ញាបនបត្រកម្រិត ISO/IEC 27001:2022 ហើយយើងប្តេជ្ញាអភិវឌ្ឍឱ្យកាន់ប្រសើរឡើងជានិច្ច។